# ពិនិត្យពិចារណាលើការប្រើប្រាស់សញ្ញាប្រយោគមួយចំនួនក្នុងភាសាខ្មែរបច្ចុប្បន្ន

ដោយលោកសាស្ត្រាចារ្យ ត្រាំ ម៉ល់
សាស្ត្រាចារ្យភាសាវិទ្យា
រាជបណ្ឌិតសភាកម្ពុជា

## សេចក្តីផ្តើម

ភាសាខ្មែរបច្ចុប្បន្នកំពុងលូតលាស់យ៉ាងខ្លាំង ទាំងផ្នែកវាក្យស័ព្ទ (ពាក្យ និង វាចាវិលាស) ទាំងផ្នែកសម្ព័ន្ធ ប៉ុន្តែ ការលូតលាស់ខ្លាំងនិងឆាប់រហ័សនេះបាននាំមកជាមួយគ្នានូវចំណុចអវិជ្ជមានមួយចំនួន រួមមានការបង្កើតពាក្យក្នុងភាពចម្រូងចម្រាស ការប្រើល្បះកម្មវាចកៈបែបបារាំង/អង់គ្លេសដែលកំពុងរកផ្លូវទៅមុខយ៉ាងតតេះតតះ ការប្រើដំណាក់ឃ្លាប្លែកៗគ្នា ។ល។

យើងមិនអាចមិនទទួលស្គាល់ថា ការលូតលាស់នេះបាននាំមកជាមួយនូវចំណុចវិជ្ជមានជាច្រើន នោះទេ ប៉ុន្តែ ក្នុងអត្ថបទនេះ ខ្ញុំមានបំណងនិយាយតែពីចំណុចអវិជ្ជមានមួយចំនួន ដើម្បីស្វែងរកលក្ខណៈសមស្របផ្អែកលើកម្មវិស័យភាព (objectivité) តាមដែលអាចធ្វើទៅបាន ចៀសអញ្ញថាភាព(subjectivité) របស់យើងម្នាក់ៗ ហើយ ខ្ញុំសុំ[១] លើកមកពិនិត្យតែបញ្ហាទាក់ទងនឹងការប្រើសញ្ញាក្នុងប្រយោគ (ឬ ហៅដោយខ្លី ថា «សញ្ញាប្រយោគ») ។ ក្នុងចំណោមសញ្ញាប្រយោគទាំងប៉ុន្មាន ខ្ញុំនឹងសិក្សាតែពីដំណាក់ឃ្លា ដែលត្រូវបានគេប្រើផ្សេងៗគ្នា ជាមួយ «និង» ជាមួយ «ឬ» ជាមួយកម្មរងទេសកាលដែលនៅខាងដើមល្បះ និង សញ្ញាប្រយោគណាខ្លះដែលបានចោទជាបញ្ហារវាងអ្នកប្រើប្រាស់អក្សរខ្មែរ ។

---

[១] សម្តេចព្រះសង្ឃរាជ ជួន ណាត បានប្រើ«សុំ»ផង «សូម»ផង ក្នុងន័យដូចគ្នា ប៉ុន្តែ លោកបានប្រើ «សុំ»ច្រើនជាង «សូម», ដូចមានជាឧទាហរណ៍ខ្លះៗ :

- "លោក លាង ហ៍បអាន ជានាយកនៃពុទ្ធសាសនបណ្ឌិត្យ បានមកសូមឱ្យខ្ញុំជួយឧបត្ថម្ភក្នុងការបោះពុម្ពគ្រា ទី៥ នេះ", (និទាន សម្រាប់បោះពុម្ពវចនានុក្រមខ្មែរ គ្រាទី ៥, ទំព័រ ង )។
- "ដល់មកកាលជាខាងចុង គ.ស. ១៩៦៧ លោកនាយកនៃពុទ្ធសាសនបណ្ឌិត្យក្រុងភ្នំពេញ បានចាត់ការបោះពុម្ពវចនានុក្រមនេះជាគ្រាទី ៥ (...), សុំឱ្យគណៈកម្មការទាំង ៤ រូបនេះឆ្លៀតពេលធ្វើការឱ្យបានសម្រេចឆាប់បន្តិច (...)", (និទាន ដដែល , ទំព័រ ឃ & ង )។
- «លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បានសុំព្រះសាសនមុនី គិម-តូរ (ចន្ទមង្គលោ) សមាជិកក្រុមជំនុំព្រះត្រៃបិដក និងលោក ញ៉ង-សឿង (...) ឱ្យទទួលបំពេញមុខងារនេះ» , (និវេទនកថា , ទំព័រ ជ )។

ខ្ញុំចាត់ទុកគម្លាត (ដំណកឃ្លា) រវាងពាក្យពីរម៉ាត់ឬកន្សោមពាក្យពីរកន្សោមថា ជាសញ្ញាដូចសញ្ញាឯទៀតដែរ ពីព្រោះគម្លាតដែលទុកលំហាពណ៌សលើក្រដាសស/ផ្ទៃរាបសម្បុពណ៌ផ្សេងៗទៅតាមពណ៌ក្រដាស/ពណ៌ផ្ទៃរាបនោះ ក៏ជាសញ្ញាដែលភ្នែកយើងមើលឃើញផងដែរ ។

## សេចក្តីអធិប្បាយ

**មុខ្យោគ** :

សព្វថ្ងៃ គេច្រើនស្គាល់ពាក្យ «ឃ្លា» តែក្នុងកន្សោមពាក្យ «ដកឃ្លា» ។ យុវជនជំនាន់ក្រោយមិនសូវស្គាល់ន័យដើមរបស់ពាក្យនេះទេ។ តាមវចនានុក្រមខ្មែរ[២] ឃ្លាជា «ល្បះពាក្យ, ល្បះសេចក្តី ដែលមានទំនងត្រូវដកឱ្យដាច់ ឱ្យឃ្លាត : សេចក្តីមួយឃ្លា, មើលកាព្យឱ្យដឹងឃ្លា, សរសេរដកឃ្លា» ។ ន័យកំណត់ដោយការពន្យល់ដូចមានមកនេះជាន័យដើមរបស់ពាក្យ «ឃ្លា» ប៉ុន្តែ ឥឡូវនេះ គេច្រើនសំដៅទៅលើគម្លាតរវាងពាក្យពីរ/កន្សោមពាក្យពីរកន្សោម (លំហ,សម្បុពណ៌ផ្សេងៗ លើក្រដាស/ផ្ទៃរាប) តែប៉ុណ្ណោះ។

ចំពោះពាក្យ «ល្បះ» ឬ «របះ» វិញ យុវជនសព្វថ្ងៃស្គាល់តែពាក្យ «ល្បះ» ក្នុងន័យថា «សេចក្តីគ្រប់គ្រាន់មួយសង្កាត់ៗ» ក្នុងការសរសេរឬក្នុងការនិយាយស្តី គឺត្រូវនឹងន័យដើមរបស់ពាក្យ«ប្រយោគ» ហើយ គេមិនសូវស្គាល់ពាក្យ «របះ» ទេ ។

ដើម្បីទាញអារម្មណ៍សាធារណជនទៅលើន័យដើមរបស់ពាក្យ «ល្បះ/របះ» នេះ គប្បីយើងពិនិត្យការពន្យល់ក្នុងវចនានុក្រមដដែល[៣] ដូចខាងក្រោម :

- «ល្បះ (លែងប្រើហើយ) មើលក្នុងពាក្យ របះ ន. និង រះ កិ. ផង»។
- «របះ ន. ការរះឱ្យមានឃ្លា ។ ឈ្មោះវណ្ណយុត្តិមួយប្រភេទ មានរូបសញ្ញាបែបនេះ (។ ) សម្រាប់រះខណ្ឌឃ្លាក្នុងសង្កាត់នៃប្រយោគវែងខ្លីនីមួយៗ» ។

រីឯពាក្យ «ប្រយោគ» វិញគេនៅឮតែក្នុងកន្សោមពាក្យ «ឃ្លាប្រយោគ» ហើយ យុវជនភាគច្រើនមិនដឹងថាពាក្យ «ប្រយោគ» មានន័យច្បាស់លាស់យ៉ាងណាផង។តាំងពីយូរយារហូតមកទល់នឹងរបបខ្មែរក្រហម «ប្រយោគជាដំណើរពាក្យដែលមានសេចក្តីគ្រប់គ្រាន់មួយសង្កាត់ៗ : សេចក្តី១ប្រយោគ[៤]» គឺត្រូវនឹងពាក្យបារាំង "phrase" ឬ ពាក្យអង់គ្លេស "sentence" ឬ ត្រូវនឹងពាក្យ "ល្បះ" ក្នុងន័យដែលគេប្រើសព្វថ្ងៃ។

**១ - ដំណកឃ្លា** :

**១.១- ការប្រើដំណកឃ្លា ជាមួយ «និង»** :

**១.១.១- ការប្រើដំណកឃ្លា ជាមួយ «និង » ដោយសាធារណជនទូទៅ**

---

[២] វចនានុក្រមខ្មែរ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧។

[៣] វចនានុក្រមខ្មែរ (-ដ-)។

[៤] វចនានុក្រមខ្មែរ (-ដ-)។

យើងម្នាក់ៗអាចសង្កេតឃើញថា ការប្រើដំណកឃ្លាជាមួយ " និង " មិនទាន់មានឯកភាពទេ : អ្នកខ្លះឥតដកឃ្លាទេ អ្នកខ្លះដកឃ្លាខាងឆ្វេង អ្នកខ្លះដកឃ្លាខាងឆ្វេងផងខាងស្ដាំផង អ្នកខ្លះដកឃ្លាក្នុងបែបលាយឡំគ្នា ។

**(១) - ការប្រើ «និង» ដោយឥតដកឃ្លា**

ការប្រើ "និង" ដោយឥតដកឃ្លាមានជាឧទាហរណ៍ ដូចខាងក្រោម :

(១.១)- «ស្ថិតនៅអូរឈើទាល (អតីតដីអភិវឌ្ឍន៍របស់ក្រុមហ៊ុនអារីស្តុត) និងដីព្រះរាជដំណាក់ (...) ។ (...) ដើម្បីធ្វើការពិនិត្យនិងធ្វើរបាយការណ៍និងស្នើសុំការណែនាំ», (អត្ថបទចុះក្នុង «រស្មីកម្ពុជា» ថ្ងៃអាទិត្យ-ច័ន្ទ ៣១-០១ ខែកក្កដា-សីហា ឆ្នាំ២០០៥ , ទំព័រ ក២ < «វិធានការការពារដីគម្រោងអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍និងដីដំណាក់ស្តេចនៅស្រែពេចស្រពិល»)។

(១.២)- «(...) សំឡាដែលរាប់នាមទាមបង្គ្រប់ជាជាន់ៗ តាមលំដាប់តាមថ្នាក់ ដូចពាក្យថា(...) គំរប់ប្រាំជាដើមនិងពាក្យថា ៖ (...), (ពូរ អ៊ុម , វេយ្យាករណ៍ខ្មែរ , បណ្ណាគារ **តឹម សេង** លេខ ២១២ វុក្ខវិថីខេមរភូមិន្ទ ឆ្នាំ១៩៥៨ , ទំព័រ ៥២ & ៥៣) ។

**(២) - ការប្រើ «និង» ដោយដកឃ្លា ខាងឆ្វេង :**

សព្វថ្ងៃគេច្រើនប្រើ «និង» ភ្ជាប់ទៅពាក្យ/កន្សោមពាក្យខាងស្ដាំ ដោយដកឃ្លាឱ្យឃ្លាតពីពាក្យ/កន្សោមពាក្យដែលនៅខាងឆ្វេង , ឧទាហរណ៍ :

(២.១)- «សូមអតិថិជនទាំងអស់ មេត្តាជ្រាប និងអនុវត្តតាមសេចក្ដីជូនដំណឹងនេះ ដោយសេចក្ដីអនុគ្រោះ», (សេចក្ដីជូនដំណឹងរបស់ក្រុមហ៊ុន AZ ក្នុងកាសែត «រស្មីកម្ពុជា» ចុះថ្ងៃពុធ ១៩ ធ្នូ ឆ្នាំ២០០៤ , ទំព័រ ក៣) ។

(២.២)- «(...) អគ្គនាយកនៃអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ...

គោរពជូនពី

មន្ត្រីទាំងអស់នៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងនាយកដ្ឋានពេទ្យការងារ » , (ការជូនពរដល់ឯកឧត្តម សេង សក្កា ចុះក្នុង «រស្មីកម្ពុជា» ថ្ងៃអង្គារ ១២-០៧-០៥ , ទំព័រ ក១) ។

(២.៣)- «(...) ដោយកិច្ចសន្យាជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ», (អត្ថបទក្នុង «រស្មីកម្ពុជា» ចុះថ្ងៃព្រហស្បតិ៍ ២៩-០៧-០៥ , ទំព័រ ក៧) ។

**(៣) - ការប្រើ "និង" ដោយដកឃ្លា ខាងឆ្វេងផង ខាងស្ដាំផង**

ចរន្តទី៣ប្រើ «និង» ដោយដកឃ្លា ខាងឆ្វេងផង ខាងស្តាំផង , ដូចមានជាឧទាហរណ៍ :

(៣.១)- « (...) សូមឯកឧត្តម មានសុខភាពល្អបរិបូណ៌ (...) ដើម្បីរួមចំណែក កសាង
ការពារ និង ដឹកនាំប្រទេសកម្ពុជា ឱ្យមានសុខសន្តិភាព
សំបូររុងរឿង រៀងតទៅ
គោរពជូនពរពី
លោក ថេង សេង និង ភរិយា (ប្រទេសបារាំង)
លោក ឈួន ហុង និង ភរិយា (ហុងកុង)»,
(ការជូនពរដល់ឯកឧត្តម ឧត្តមសេនីយ៍ ហេង ពៅ ចុះក្នុង «រស្មីកម្ពុជា»
ថ្ងៃព្រហស្បតិ៍ ៣០-០៦-០៥ , ទំព័រ ក១) ។

(៣.២)- « (...) ពិសេសសូមឱ្យសហជីវិនសម្រេចបាននូវស្នាដៃថ្មីៗថែមទៀត (...)»
សូមគោរពជូនពី
«សហជីវិន សហជីវិនី នៃគណៈកម្មការប្រតិបត្តិក្រុង
ការិយាល័យប្រតិបត្តិខណ្ឌ និង ការិយាល័យប្រតិបត្តិសង្កាត់» ,
(ការជូនពរដល់ សហជីវិន ម៉ម ប៊ុននាង ចុះក្នុង «រស្មីកម្ពុជា»
ថ្ងៃសៅរ៍ ០៩-០៧-០៥ , ទំព័រ ក១) ។

(៣.៣)- « (...) នាំចូលឱសថសម័យ និង បរិក្ខារពេទ្យ (...)»,
(ដំណឹងជ្រើសរើសបុគ្គលិកនៃក្រុមហ៊ុន មាស្ទ័រ ហ្វាម៉ា គ្រុប ចុះក្នុង
«រស្មីកម្ពុជា» ថ្ងៃព្រហស្បតិ៍ ០៧-០៧-០៥ , ទំព័រ ខ៣) ។

(៣.៤)- « (...) ត្រូវការជ្រើសរើសនារីម៉ាស្សា ខ្មែរ និង វៀតណាម (...)»,
(ដំណឹងជ្រើសរើសនារី ម៉ាស្សា ផ្ទះសំណាក់ ឈារី ហ្វៀអឺ ចុះក្នុង
«រស្មីកម្ពុជា» ថ្ងៃព្រហស្បតិ៍ ០៧-០៧-០៥ , ទំព័រ ខ៣) ។

(៤) - **ការប្រើ "និង" ដោយដកឃ្លា ក្នុងបែបលាយឡំគ្នា :**

ចរន្តទី៤ប្រើដំណកឃ្លាជាមួយ «និង» ក្នុងបែបលាយឡំគ្នា , ឧទាហរណ៍ :

(៤.១)- «អ្នកជំនួញ និង ពលរដ្ឋគ្រប់រូបគប្បីការពារការឆបោក ក្លែងបន្លំ និងអំពើទុច្ចរិត» ,
(ការផ្សាយដំណឹងពីមន្ទីរសារការីនៃព្រះរាជាណាចក្រកម្ពុជា ចុះក្នុង «រស្មីកម្ពុជា»
ថ្ងៃព្រហស្បតិ៍ ៣០-០៦-០៥ , ទំព័រ ក១) ។

(៤.២)- « (...) សម្របសម្រួលរវាងប្រជាសហគមន៍ជនជាតិនិងក្រុមហ៊ុនចិន (...) ។

(...) កន្លែងខ្លះសហគមន៍ទាមទារដីទំហំ៦គីឡូម៉ែត្របួនជ្រុង និងកន្លែងខ្លះទាមទាររហូតដល់១០គីឡូម៉ែត្របួនជ្រុង ។» ) , («រស្មីកម្ពុជា» ថ្ងៃអាទិត្យ-ច័ន្ទ ទី៣១-០១ ខែកក្កដា-សីហា ឆ្នាំ២០០៥ , ទំព័រ ក៥ < «អាជ្ញាធរនិងគណៈកម្មការអន្តរក្រសួងនិយាយខុសគ្នា» , ករណីដីរូងដីសាន ដោយ យិន លាងគង់) ។

(៤.៣)- «លោកអភិបាលក្រុងបានអះអាងបែបនេះនៅក្នុងឱកាសដែលរូបលោករួមជាមួយសហការីនិងលោកឧត្តមសេនីយ៍ ម៉ៅ សុផាន់ (...) ទៅពិនិត្យមើលការងារបង្កបង្កើនផលស្រូវ (...) ។ (...) ទម្លាក់មកតាមប្រឡាយមេកាត់តាមសង្កាត់ពងទឹក ព្រៃវែង ប្រទះឡាង និងសាក់សំពៅ ដើម្បីឱ្យប្រជាកសិករបានទឹកស្រែគ្រប់ៗគ្នា។» , ( «រស្មីកម្ពុជា» ថ្ងៃអាទិត្យ-ច័ន្ទ ទី០៧-០៨ ខែសីហា ឆ្នាំ២០០៥, ទំព័រ ក៣) ។

**១.១.២- ការប្រើជំនាកឃ្លា ជាមួយ «និង» ក្នុងវចនានុក្រមខ្មែរ ដោយសម្តេចព្រះសង្ឃរាជ ជួន ណាត :**

**(១) - ឥតដកឃ្លា :**

ទាក់ទងនឹងពាក្យ «និង» វចនានុក្រមខ្មែរបានពន្យល់ ដោយឥតដកឃ្លា ដូចនេះ : «(បារ. ៥ ) សព្ទជាសន្ធាន ជាទូន្ទសម្រាប់និយាយតពាក្យឬតឃ្លារបះពីមួយទៅមួយ ដែលមានដំណើរសេចក្ដីថា ទាំង, ព្រមទាំង, ផង, នេះផង, នុ៎ះផង : អ្នកនិងខ្ញុំ; គោនិងក្របី; ផ្ទះនេះ ផ្ទះនុ៎ះនិងផ្ទះឯណោះ; សុខនិងទុក្ខ; ទៅនិងមិនទៅ; ឱ្យនិងមិនឱ្យ; យកថានទិនផ្តិលមកផង ។ល។» ។

ក្នុងករណីផ្សេងទៀត សម្តេចព្រះសង្ឃរាជ ជួន ណាត ក៏បានប្រើ «និង» ដោយឥតដកឃ្លាដែរ , ដូចមានឧទាហរណ៍ ខាងក្រោម :

- «ខ្ញុំនិងគណៈកម្មការទាំង៤រូបក៏បានព្រមព្រៀងគ្នាជាឯកឆន្ទ: (...) » , (និទាន , សម្រាប់បោះពុម្ពវចនានុក្រមខ្មែរគ្រា ទី៥ , ទំព័រ ច) ។
- «សៀវភៅវចនានុក្រមខ្មែរភាគទី ១ នេះ នៅខ្វះមេពាក្យច្រើន ទាំងសេចក្តីអធិប្បាយនិងរបៀបរៀបមេពាក្យ ក៏មានភ្លាំងភ្លាត់ខ្លះ» ។ , (និវេទនកថា , ទំព័រ ជ) ។

**(២)- ដកឃ្លាខាងឆ្វេង :**

- «លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បានសុំព្រះសាសនមុនី គិម-តួរ (ចន្ទមង្គលោ) សមាជិកក្រុមជំនុំព្រះត្រៃបិដក និងលោក ញ៉ង-សឿង (...) ឱ្យទទួលបំពេញមុខងារនេះ», (និវេទនកថា, ទំព័រ ជ) ។

**(៣)- ដកឃ្លា ខាងឆ្វេងផង ខាងស្តាំ :**

- «ស្រះ ឯ និង ឰ នេះក៏ត្រូវទុកដែរ , ប៉ុន្តែ ឰ នេះទុកសម្រាប់ប្រើបន្តិចបន្តួច (...) ,

(និទាន , ទំព័រ ក) ។

- «ត្រង់ខ ១១ និង ខ ១២ គណៈកម្មការដំបូងបង្អស់គ្រាន់តែមានយោបល់យល់ឃើញ ប៉ុន្តែ ពុំអាចបានសម្រេចដោយដាច់ខាតទេ (...) , (និទាន, ទំព័រ គ)។

**(៤)- ដកឃ្លា ដោយបែបលាយឡំគ្នា :**

- «ក្នុងគ្រានេះ ខ្ញុំលៃពេលម៉ោង (...) , បានដកស្រង់យកកាព្យ (...) , សុភាសិតនិងភាសិតបុរាណខ្លះ , និង កាព្យរបស់ខ្ញុំខ្លះ (...) , (និទាន , ទំព័រ ង)។

សង្កេត :

១- ក្នុងនិទាន (សេចក្តីផ្តើម) & ក្នុងនិវេទនកថា សម្រាប់បោះពុម្ពវចនានុក្រមខ្មែរគ្រាទី៥ សម្តេចព្រះសង្ឃរាជជួន ណាត បានប្រើ «និង» ដោយឥតដកឃ្លាចំនួន២ដង, ដកឃ្លាខាងឆ្វេងចំនួន១ដង , ដកឃ្លាខាងឆ្វេងផងខាងស្តាំផងចំនួន២ដង , ដកឃ្លាតាមបែបលាយឡំគ្នាចំនួន១ដង ។

២-ក្នុងឧទាហរណ៍ខាងលើទាក់ទងនឹង«ដកឃ្លាបែបលាយឡំគ្នា» ពាក្យ «និង» ទី១ភ្ជាប់កន្សោមតូចពីរឱ្យទៅជាកន្សោមធំមួយ ហើយកន្សោមធំនេះត្រូវភ្ជាប់ទៅកន្សោមធំមួយទៀត។ រវាងកន្សោមធំទាំងពីរនេះ សម្តេចព្រះសង្ឃរាជ ជួន ណាត បានប្រើ «និង» ដោយដកឃ្លាខាងស្តាំផងខាងឆ្វេងផង ព្រមទាំងមានក្បៀសផងទៀត : លោកបានចែកឋានានុក្រមពីទាបទៅខ្ពស់ : ការប្រើ «និង» បែបនេះមិនចំជាបែបលាយឡំគ្នាទេ។

### ១.២ - ការប្រើដំណកឃ្លា ជាមួយ «ឬ» :

#### ១.២.១- ការប្រើដំណកឃ្លា ជាមួយ «ឬ» ដោយសាធារណជនទូទៅ

ដំណកឃ្លាជាមួយពាក្យ «ឬ» ក៏ដូចគ្នានឹងពាក្យ «និង» ដែរ ត្រូវបានគេប្រើផ្សេងៗគ្នា ដូចមានឧទាហរណ៍តទៅ :

**( ១) - ឥតមានដកឃ្លា :**

(១.១)- «(...) ដើម្បីយកប្រាក់ទៅធ្វើអាជីវកម្មដទៃឬបំប៉ន់បែបផែនរស់របស់ម្ចាស់សាលាទាំងនោះឬយ៉ាងណានោះទេ។ (...)» , («រស្មីកម្ពុជា» ថ្ងៃអង្គារ-២៣-០៨-០៥ . ទំព័រ ក៧ < គុណភាពឧត្តមសិក្សាកង្វល់របស់មាតាបិតា ដោយ សុខ ចន្ថា ក្នុងលិខិតមិត្តអ្នកអាន)។

(១.២)- «សាលាក្រុងភ្នំពេញបានសម្រេចធ្វើការងារ (...) ដោយហ្មត់ចត់បំផុតមិនអាចអត់ឱនឬលើកលែងទោសឱ្យក្រុមបើកឡានបំផ្លាញសួនច្បារ (...)» , («រស្មីកម្ពុជា» ថ្ងៃអង្គារ-២៣-០៨-០៥ , ទំព័រ ក៦ < ស្គាល់មុខរថយន្ត២គ្រឿងដែលបើកឡើងបំផ្លាញសួនច្បារសម្តេចហ៊ុនសែន ដោយ វ៉ាម៉ន)។

**(២)- ដកឃ្លាខាងឆ្វេង :**

(២.១)- «(...) បើមានធ្វើលេខអាស៊ី ឬលេខអឺរ៉ុប ឬលេខអាគាំងទៀត ក៏ខ្ញុំទៅធ្វើដែរ។ (...)» , («រស្មីកម្ពុជា» ថ្ងៃសៅរ៍-២០-០៨-០៥ , ទំព័រ ក៧ <ជួយជាតិពួកយើង ដោយវ៉ូហ្សា)។

(២.២)- «(...) ខ្ញុំមិននិយាយពីតម្លាភាព ឬមិនតម្លាភាពទេ (...)», («រស្មីកម្ពុជា» ថ្ងៃសៅរ៍-២០-០៨-០៥ , ទំព័រ ក៧ < រឿងអាស្រូវដូរទីតាំងនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ដោយ យិន - លាងគង់)។

**(៣)- ដកឃ្លាខាងស្ដាំ :**

«(...) មន្ត្រីប៉ូលិសប្រចាំនៅក្រុងបាងកកបានឱ្យដឹងថា តទៅនឹងមានការដាក់យាមកាមតាមតំបន់ស្ងាត់ឬ ច្រកផ្លូវគ្មានមនុស្សចេញចូលច្រើន (...)» , («រស្មីកម្ពុជា» ថ្ងៃសុក្រ-២៦-០៨-០៥ , ទំព័រ ក៩ < រកឃើញតំបន់ចាប់រំលោភស្ត្រីរាប់មិនអស់មួយនៅទីក្រុងបាងកក)។

**(៤)- ដកឃ្លា ខាងឆ្វេងផង ខាងស្ដាំផង :**

«(...) -កំរិតវប្បធម៌ : បញ្ចប់មហាវិទ្យាល័យ ឬ សកលវិទ្យាល័យ ផ្នែក (...)» , (ដំណឹងជ្រើសរើសបុគ្គលិក ធនាគារ វឌ្ឍនៈអាស៊ីចំកាត់ ចុះក្នុង «រស្មីកម្ពុជា» ថ្ងៃអង្គារ ២៣-០៨-០៥ , ទំព័រ ខ៧)។

**(៥)- ដកឃ្លា ដោយបែបឈាយឡំគ្នា :**

«(...) សមត្ថកិច្ចរបស់លោកគ្មានលទ្ធភាពឬបទបញ្ជាពីអាជ្ញាធរខេត្តឱ្យដេញ ឬឱ្យសង្ឃទាំងនោះរុះរើខ្លោងទ្វារនោះចេញវិញឡើយ។ (...)» , («រស្មីកម្ពុជា» ថ្ងៃសៅរ៍-២០-០៨-០៥, ទំព័រ ក១០ < ព្រះសង្ឃផ្ដើលទៅចាប់ដីធ្វើវត្តនៅជើងភ្នំព្រះវិហារ ដោយ បាយ័ន)។

(១.២.២)- <u>ការប្រើដំណកឃ្លា ជាមួយ «ឬ» ក្នុងវចនានុក្រមខ្មែរ ក្រោមការទទួលខុសត្រូវ/ដោយ សម្ដេចសង្ឃរាជ ជួន ណាត</u> :

**(១)- ឥតមានដកឃ្លា :**

(១.១)- «អក្សរអឃោសៈនៅពីខាងដើមឬពីខាងលើអក្សរដែលត្រូវសម្លាប់ (...)» , (និទាន, សម្រាប់បោះពុម្ពវចនានុក្រមខ្មែរគ្រាទី ៥, ទំព័រ ខ)។

(១.២)- «កិរិយាសព្ទឬគុណសព្ទទោល (...) មិនតម្រួតឬមិនគ្រវាត់ (...)» , (និទាន, ទំព័រ គ)។

(១.៣)- «កិរិយាសព្ទឬគុណសព្ទដែលមានអក្សរតម្រួតឬផ្ញើជើង (...)» , (និទាន, ទំព័រ គ)។

**(២)- ដកឃ្លា ខាងឆ្វេងផង ខាងស្ដាំផង :**

(២.១)- «(...) កុំប្រើជា ឱយ ឬ អោយ ព្រោះសម្ដីខ្មែរយើង (...)» , (និទាន, ទំព័រ ក)។

(២.២)- «(...) សំឡេងជា អោវ ឬ អៅ នេះក៏ត្រូវទុក (...)» , (និទាន , ទំព័រ ខ)។

(២.៣)- «(...) សម្គម ឬ សំគម , សម្ដី ឬ សំដី ជាដើម (...)» , (និទាន , ទំព័រ ឆ)។

(២.៤)- «(...) ជា កិរិយាសព្ទ ឬ នាមសព្ទ ជាដើម (...) ។ (...) ភាសាអ្វី ឬ ក្លាយចេញមក ពីភាសាអ្វី, (...)» , (សេចក្តីប្រាវព្វរបស់ក្រុមជំនុំរៀបចំវចនានុក្រមខ្មែរ , ទំព័រ ថ )។

(២.៥)- «ការ ៤ ន. (បា. សំ. កាយ៌ ឬ ការ្យ) កិច្ច ឬ អំពើដែលត្រូវធ្វើ (...)» , (វចនានុក្រមខ្មែរ បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧)។

(២.៦)- «ការពារ កិ. ឃាត់ខាំង , រាំងរា , មិនឱ្យសត្រូវចូលដល់ខ្លួន ឬ ដល់លំនៅ (...)» ,' (វចនានុក្រមខ្មែរ ដដែល)។

**( ៣) - ដកឃ្លា ដោយបែបលាយឡំគ្នា :**

ក្នុងសេចក្តីពន្យល់ទាក់ទងនឹងពាក្យ «ឬ» ផ្ទាល់ ការប្រើដំណកឃ្លាមានបែបលាយឡំគ្នា ដូចនេះ : «ឬ និ. ពាក្យនិបាតសម្រាប់និយាយ ដោយសេចក្តីសង្ស័យមិនប្រាកដ, មិនដាច់ស្រេច, មិនអស់មិនហើយ : មិនមែនឬ? , មានដែរឬ?; មាសឬប្រាក់?។ ឬក៏ ពុំនោះក៏ : ថ្ងៃនេះ ឬស្អែក ឬក៏ខានស្អែក» ។

សង្កេត :

(១)- ទាក់ទងនឹងដំណកឃ្លាខាងឆ្វេង សម្តេចព្រះសង្ឃរាជ ជួន ណាត បានប្រើពាក្យ «ឬ» ក្នុងន័យផ្សេងពី «សេចក្តីសង្ស័យមិនប្រាកដ, មិនដាច់ស្រេច, មិនអស់មិនហើយ» គឺ ក្នុងន័យ «ឬក៏ ពុំនោះក៏» ដូច្នេះ ខ្ញុំគិតថា ការប្រើដំណកឃ្លា ក្នុងឧទាហរណ៍ខាងលើ មិនចំជាបែបលាយឡំគ្នាទេ។

(២)- ចំពោះករណី «ឬ» នេះ វចនានុក្រមខ្មែរបានប្រើដំណកឃ្លាខាងស្តាំផងខាងឆ្វេងផង ដ៏ច្រើនលើសលប់ជាងដំណកឃ្លាតាមបែបផ្សេងទៀត ជាពិសេស ក្នុងការពន្យល់ពាក្យ (ដូចមានក្នុងឧទាហរណ៍ខាងលើ)។

**១.៣- សម្រង់ការប្រើកម្មវទេសកាលនៅដើមឈ្មោះ :**

**១.៣.១- ការប្រើកម្មវទេសកាលនេះ ដោយសារការណាជននូនៅ :**

**( ១) - ឥតមានដកឃ្លា :**

ការដាក់កម្មវងទេសកាលនៅដើមឈ្មោះឱ្យជាប់នឹងប្រធាននៃប្រេឌីកាត់ (< កិរិយាស័ព្ទ ) មានជាឧទាហរណ៍ខ្លះៗ ដូចខាងក្រោម :

- « ទាក់ទងនឹងហេតុការណ៍ខាងលើនេះប្រភពព័ត៌មានពីអ្នកស្រុកនៅកន្លែងកើតហេតុបានឱ្យដឹងថា (...)» , ( «រស្មីកម្ពុជា» ថ្ងៃអង្គារ-០៩-០៨-០៥ , ទំព័រ ក៧ < ឡើងលបកូនក្រមុំគេកណ្តាលយប់ត្រូវប៉ូលីសឃាត់ខ្លួន ដោយ ពេជ្រ និល)។
- «(...)។ បច្ចុប្បន្នស្រុកមានទំនប់ស្ទាក់ទឹកចំនួនពាកន្លែង (...)», («រស្មីកម្ពុជា» ថ្ងៃអង្គារ-០៩-០៨-០៥ , ទំព័រ ក៣ < ខេត្តកំពង់ធំៈធ្វើទំនប់ស្ទាក់ទឹកនិងផ្លាស់ប្តូរទម្លាប់ធ្វើស្រែទើបអាចរំដោះបាននូវកង្វះខាតស្បៀង ដោយ រចនា)។

**( ២) - ដោយមានដកឃ្លា ចន្លោះកម្មវទេសកាល និង ប្រធាននៃប្រេឌីកាត់ :**

- «(...) ។ បន្ទាប់មក អ្នកបើកបរបានបើកទ្វារចុះចេញពីឡានដើរធ្វើព្រងើយត្រឡប់ទៅ

កន្លែងផឹកស៊ីវិញ។ (...)», («រស្មីកម្ពុជា» ថ្ងៃអាទិត្យ-ច័ន្ទ ទី២១-២២ ខែសីហា ឆ្នាំ២០០៥ , ទំព័រ ក៦ < សែនចិនស្រវឹងឃ្លួនបើកឡានបុកកូនខ្មែរបួសធ្ងន់៥ ស្រាល ម្នាក់ ដោយ អ្នកា)។

- « ឆ្នាំ២០០៤ កម្ពុជាផលិតអង្ករបាន៤លានតោន។ (...)», («រស្មីកម្ពុជា» ថ្ងៃអង្គារ-០៩-០៨-០៥ . ទំព័រ ក៧ < ប្រព័ន្ធទីផ្សារពាណិជ្ជកម្មនៅកម្ពុជាសាំញ៉ាំច្រើន ដោយ ដកស្រង់សម្ដីលោក អ៊ុន-ប៊ុនថា អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម ក្នុងសិក្ខាសាលាមួយនាក្រុងព្រះសីហនុ កាលពីដើមខែកក្កដា)។

( ៣) - **ដកឃ្លា ដោយបែបលាយឡំគ្នា :**

- « ថ្ងៃមុន នាយអ្នកា លោតកញ្ឆាញ់ចេក (...)។ ថ្ងៃមុនអាក្លើខ្ញុំវារកស៊ីខាងធ្វើកុននោះ វាប៉ាវលោកអ្នកអន្ទ្រើសខាងវប្បធម៌ម៉ាតុ (...)» , («រស្មីកម្ពុជា» ថ្ងៃអាទិត្យ-ច័ន្ទ ទី ២១-២២ ខែ សីហា ឆ្នាំ ២០០៥ , ទំព័រ ក៧ < អ្នកវប្បធម៌ស្រុកយើង ដោយ រ៉ូហ្សា)។

**១.៣.២- ការប្រើកម្ទេចទេសកាលនៅដើមល្បះ ក្នុងវចនានុក្រមខ្មែរ ដោយ សម្ដេចព្រះសង្ឃរាជ ជួន ណាត :**

ចំពោះករណីនេះ សម្ដេចព្រះសង្ឃរាជ **ជួន ណាត** ដកឃ្លានៅចន្លោះកម្ទេចទេសកាលនិងប្រធាននៃប្រយោគ ហើយ នៅពេលខ្លះ លោកបានប្រើសញ្ញាក្បៀសថែមទៀតផង , ឧទាហរណ៍ :

- «(...)។ មុននឹងផ្ដើមការរៀបរៀង , គណៈកម្មការបានប្រឹក្សាយ៉ាងយូរ (...)» , (និទាន, ទំព័រ ក)។

-«ក្នុងការបោះពុម្ពគ្រាទី ៤ នេះ លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បានសុំឱ្យអាត្មាជួយរៀបចំបន្ថែម (...)» , (និវេទនកថា , ទំព័រ ជ)។

**១.៤- ទស្សនៈកលក្ខណៈសមស្រប ផ្អែកលើលក្ខណៈសម្ព័ន្ធ :**

សម្ព័ន្ធវិទូដ៏ល្បីល្បាញឈ្មោះឈូអាម ឆុមស្គី បានបង្ហាញផ្លូវក្នុងការសិក្សាពីសម្ព័ន្ធ ដោយចែកល្បះជាកន្សោម ដែលមានកន្សោមនាម, កន្សោមកិរិយា និង កន្សោមនិបាត។ គេអាចចែកកន្សោមគោលទាំងនេះជាកន្សោមតូចៗតទៅទៀត ប៉ុន្តែ សន្ធានឈ្នាប់ (conjonction de coordination) មិនអាចបង្កើតកន្សោមទេ វាគ្រាន់តែជាចំណងសម្រាប់ចងកន្សោមពីរ ហើយ គេអាចចងឱ្យតឹង (ឥតដក ឃ្លា) ឬ ចងធូរៗ (ដកឃ្លាសងខាង)។ សម្ដេចព្រះសង្ឃរាជ **ជួន ណាត** បានយល់លក្ខណៈសម្ព័ន្ធច្រើន ជាងយើង តាំងពីប៉ុន្មានទសវត្សរ៍ មក ហើយ ជាពិសេសតាមរយៈការប្រើសន្ធានស័ព្ទ «ឬ» របស់លោក និង តាមរយៈការប្រើដំណកឃ្លានៅចន្លោះកម្ទេចទេសកាលដើមល្បះនិងប្រធាននៃប្រយោគ ។ លក្ខណៈសម្ព័ន្ធអនុញ្ញាតឱ្យយើងសន្និដ្ឋានថា ការដកឃ្លា

ខាងឆ្វេងសន្ធានស័ព្ទ «និង» ឬ ខាងឆ្វេង/ខាងស្តាំសន្ធាន ស័ព្ទ «ឬ» ជាទង្វើ មិនសមស្របទេ ពីព្រោះ បើគេចង់ដកឃ្លា គេត្រូវដកជាកន្សោមៗ ។

ភាសាវិទ្យាបានយកគណិតវិទ្យានិងរូបវិទ្យាធ្វើជាគំរូ ហើយ បានខ្ចីវិធីមួយចំនួនពីវិទ្យាសាស្ត្រជាក់[៥] ទាំងពីរនេះ ដូចជា អាគុយម៉ង់, ចតុត្ថសមាមាត្រ[៦] (quatrième proportionnelle), ដំណាក់កត្តារួម (mise en facteur commun) ជាដើម ។ ក្នុងសម្ព័ន្ធ គេប្រើដំណាក់កត្តារួមជាញឹកញាប់ ។ ដើម្បីជាការរំលឹកឡើងវិញ ខ្ញុំសុំលើកយកដំណាក់កត្តារួមសាមញ្ញមួយមកពិនិត្យ គឺ $a ( b + c )$ ។ ដោយ $a$ ជាកត្តារួមរបស់ $b$ ផងនិងរបស់ $c$ ផង គេត្រូវប្រើវង់ក្រចកដើម្បីកុំឱ្យ $a$ ជាប់នឹង $b$ តែម្នាក់ឯង : បើគេដាក់ដូចនេះ $ab + c$ , $a$ ជារបស់ $b$ ម្នាក់ឯង វាមិនមែនជារបស់ $c$ ផងទេ ។ ក្នុងសម្ព័ន្ធក៏ដូច្នេះដែរ គេមិនត្រូវដាក់កត្តារួមសម្រាប់កន្សោមពីរឱ្យជាប់នឹងកន្សោមណាមួយ តែម្នាក់ឯងនោះទេ ។ ដោយសំអាងលើអ្វីៗដែលទើបបានរៀបរាប់មកនេះ ខ្ញុំអាចសន្និដ្ឋានថា :

(១)- សម្ព័ន្ធខាងស្តាំនេះមានភាពសមស្រប : «(...) សរសេរភាសា ខ្មែរ និង អង់គ្លេស» , ( < ដំណឹងជ្រើសរើសបុគ្គលិក ចុះក្នុង «រស្មីកម្ពុជា» ថ្ងៃអង្គារ-២៣-០៨-០៥ , ទំព័រ ខ៧)។

(២)- រីឯសម្ព័ន្ធនេះវិញ វាឥតមានភាពសមស្របទេ : «(...) ប្រធាននាយកដ្ឋាននេះ និងមន្ត្រីក្រោមឱវាទមួយចំនួនបានឃុបឃិតគ្នា (...)» , ពីព្រោះ កត្តារួម «បានឃុបឃិតគ្នា» ត្រូវបានគេភ្ជាប់ទៅឱ្យ «មន្ត្រីក្រោមឱវាទមួយចំនួន»តែម្នាក់ឯង, (ដកស្រង់ចេញពី «រស្មីកម្ពុជា» ចុះថ្ងៃសៅរ៍ ២០-០៨-០៥ , ទំព័រ ក១ < រឿងអាស្រូវដូរទីតាំងនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ដោយ យិន លាងគង់)។

**២- សញ្ញាក្បៀស :**

សញ្ញានេះត្រូវបានអ្នកប្រើប្រាស់អក្សរខ្មែរខ្លះប្រកាសមិនឱ្យប្រើដោយហេតុថា វាជាសញ្ញាខ្ចីពីក្រៅ។ ចំពោះបញ្ហានេះ ខ្ញុំសុំស្រង់ល្បះមួយរបស់សម្តេចព្រះសង្ឃរាជជួន **ណាត** មកពិនិត្យពិចារណាឱ្យឃើញថា តើលោកមានការភាន់ច្រឡំឬយ៉ាងណា ដ្បិតលោកបានប្រើសញ្ញានេះយ៉ាងសន្ធឹកសន្ធាប់ក្នុងវចនានុក្រមរបស់លោក ។ ប៉ុន្តែ មុននឹងពិនិត្យពិចារណាលើល្បះរបស់លោក ខ្ញុំសុំរំលឹកថា សញ្ញាប្រើក្នុងប្រយោគ (ឬ សញ្ញាប្រយោគ) បង្កើតដោយបុព្វបុរសខ្មែរ មានតែមួយចំនួនតូចដូចសញ្ញាខណ្ឌ, សញ្ញាខណ្ឌចប់, បរិយោសាន, ដំណកឃ្លា, បេយ្យាលៈ, សញ្ញាចុចពីរគូស,...។រីឯសញ្ញាឯទៀត ចំនួន២៥ ជាសញ្ញាខ្ចីពីក្រៅ រួមមានសញ្ញាបូក, សញ្ញាសង, សញ្ញាស្មើ, អត្ថន្តរៈ, វង់ក្រចក, វ៉ាត់, ឃ្នាប, សញ្ញាសួរ, សញ្ញាឧទាន, ព្រួញ ។ ល។

---

[៥] គេច្រើនហៅវិទ្យាសាស្ត្រទាំងពីរនេះ (គណិតវិទ្យានិងរូបវិទ្យា) ថា ជាវិទ្យាសាស្ត្រពិត ដូច្នេះ វិទ្យាសាស្ត្រឯទៀតៗ (ដូចវិទ្យាសាស្ត្រសេដ្ឋកិច្ច, វិទ្យាសាស្ត្រនយោបាយ, ភូមិវិទ្យា, ប្រវត្តិវិទ្យា, ភាសាវិទ្យា ,...) ជាវិទ្យាសាស្ត្រក្លែងក្លាយ ។ ដើម្បីចៀសបញ្ហាដែលអាចចោទឡើងបែបនេះ ខ្ញុំសុំប្រើកន្សោមពាក្យ «វិទ្យាសាស្ត្រជាក់» ជំនួសកន្សោមពាក្យ «វិទ្យាសាស្ត្រពិត» វិញ ។

[៦] ពាក្យ «ចតុត្ថសមាមាត្រ» ជាវាក្យសព្ទខ្ចីពីវចនានុក្រម បារាំង-ខ្មែរ របស់លោក តិប យក់ & ថាវ គន្ធ បណ្ណាគារ ម៉ុន ឆាង, ភ្នំពេញ, ១៩៦៤ (សូមមើលពាក្យ "proportionnel") ។

**២.១- សម្រង់សេចក្ដីមួយល្បះ របស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ដើម្បីជាឧទាហរណ៍ :**

នេះជាល្បះដែលខ្ញុំបានបង្អើបនៅកថាខណ្ឌខាងលើ : «ក្នុងសិលាចារឹក ខ្មែរបុរាណច្រើនប្រើ រ ពេញតួ, សម្រាប់ប្រើដាក់លើអក្សរចុង[៧] ដើម្បីធ្វើអក្សរតួដើមបន្ទាប់នោះឱ្យមានសូរសំឡេងញ៉រ, ប្រើចំពោះតែភាសាសំស្រ្កឹតឬសំស្រ្កឹតក្លាយ[៨], ដូចជា គ៌ភ៌ , ទុគ៌ត , ទុព៌ល , ធម៌ , បព៌ត , ព័ណ៌ , ធម៌អាថ៌ , ជាដើម ; ប៉ុន្តែបើមាន ដែលទើសពិបាកសរសេរនោះ ត្រូវដាក់អក្សរ រ ពេញតួពីលើជើងអក្សរខាងចុងវិញ, ដូចជា ទ្ធ្រិក្ស , មូ្ត្រ , រាមកេ្ត្រ, តិ្រយ , អន្សតិ្រយ ជាដើម; ចួនកាល មិនមានស្រះទើសទែងទេ ប៉ុន្តែ គួរឱ្យច្រឡំពិបាកអានក៏ត្រូវ ដាក់តួ រ លើ ជើងអក្សរខាងចុងបានដែរ, ដូចជា កម៌និ , អស្ចារ្យ៍ , អាចារ្យ៍ , ប្រើជា ក័រ្មន , អស្ចារ្យ, អាចារ្យ ជាដើម(ប្រើ សម្រួលឱ្យងាយមើលងាយថា) ។ បើមានអក្សរ រ ជាតួប្រកបពីខាងចុង , នឹងប្រើជា *របាទ* (រេផៈ) នេះផង ពុំបានឡើយ , ដូចជា ជ័រ , ដើមសង្ហ៊ុរ , ញ៉រ , ទទ័រ ជាដើម (សរសេរយ៉ាងនេះត្រឹមត្រូវ ហើយ) កុំសរសេរជា ជ័រ៌ , ...ទទ័រ៌ ឬ ជារ៌ , ... ទទារ៌ ឬក៏ ជារ៌ , ... ទទារ៌ ដូច្នេះឡើយ» ។

**២.២- ការវិភាគពិចារណា :**

សម្ដេចព្រះសង្ឃរាជ **ជួន ណាត** ប្រាកដជាបានពិចារណាគ្រប់ជ្រុងជ្រោយលើបញ្ហាអក្សរសាស្ត្រខ្មែរ , លោកប្រាកដជាបានឈ្វេងយល់ថា ខ្មែរបានខ្ចីសញ្ញាប្រយោគពីក្រៅជាច្រើន ដូច្នេះហើយ លោកឥតមានគំនិតចង្អៀតចង្អល់ទេ លោកបានប្រើសញ្ញាក្បៀសជាច្រើន។

បើលោកមិនប្រើសញ្ញានេះនៅកន្លែងខ្លះ ហើយ ប្រើតែដំណកឃ្លា ដូចអ្នកខ្លះគេចង់បាននោះ លោកក៏អាចធ្វើបានដែរ ប៉ុន្តែបញ្ញាញាណរបស់យើងមិនអាចមិនទទួលស្គាល់ថា ល្បះរបស់លោក (ដែលក្នុងនោះមានប្រើសញ្ញាក្បៀស) មានភាពច្បាស់ល្អជាងការប្រើតែដំណកឃ្លានោះទេ។

ម្យ៉ាងទៀត កន្សោម «ប្រើចំពោះតែភាសាសំស្រ្កឹតឬសំស្រ្កឹតក្លាយ» ត្រូវបានសម្ដេចព្រះសង្ឃរាជ ដាក់សញ្ញាក្បៀសអមសងខាងពីព្រោះលោកទុកសេចក្ដីរបស់កន្សោមនេះ ជាសេចក្ដីបញ្ជាក់បន្ថែមដែលតាមធម្មតា គេប្រើវង់ក្រចក[៩]។ បើគ្មានវង់ក្រចកឬសញ្ញាក្បៀសនៅសងខាងទេ កន្សោមនេះ ត្រូវភ្ជាប់ទៅពាក្យទាំងប៉ុន្មាននៅខាងស្ដាំៈ ក្នុងករណីនេះ ល្បះមានន័យប្លែកបន្តិចពីន័យដែលលោកចង់បង្ហាញ។

---

[៧] ដោយយើងគ្មានលទ្ធភាពដាក់អក្សរ រ ពេញតួលើតួអក្សរឯទៀត សូមសាធារណជនជ្រាបថា គឺនៅកន្លែងដែលមានសញ្ញារបាទនេះហើយ ដែលខ្មែរបុរាណដាក់អក្សរ រ ពេញតួ។

[៨] សូមមើលពាក្យ «របាទ» ក្នុងវចនានុក្រមខ្មែរ (ជ.ណ.ម) ។

[៩] វង់ក្រចកក៏ជាសញ្ញាខ្ចីពីក្រៅមកខ្មែរ។

**យោបល់សរុប :**

ក្នុងអត្ថបទដែលមានចំណងជើងថា : «ពិនិត្យពិចារណា លើការប្រើប្រាស់សញ្ញាប្រយោគមួយចំនួនក្នុងភាសាបច្ចុប្បន្ន» នេះ ខ្ញុំបានខំស្វែងរកលក្ខណៈកម្មវិស័យ ដើម្បីបង្ហាញឱ្យឃើញថា តើគួរសរសេរបែបណា ដើម្បីឱ្យមានភាពសមស្របតាមលក្ខណៈសម្ព័ន្ធ និង ដើម្បីបង្ហាញឱ្យឃើញស្រួលៗថា តើសញ្ញាប្រយោគណាខ្លះជាសញ្ញាខ្ចីពីក្រៅ ។ ខ្ញុំបានខំពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ ប៉ុន្តែ ការខ្វះចន្លោះ ប្រាកដជានៅមាន ដូច្នេះ មានតែការពិគ្រោះយោបល់គ្នាទេ ទើបអាចឱ្យយើងដើរផ្លូវត្រូវ ។ ខ្ញុំបានខំចៀសអញ្ចាថាភាព ប៉ុន្តែបើមាននៅសេសសល់ សូមមេត្តាជួយរំលឹកផង ។


## គន្ថនិទ្ទេសសង្ខេប

**ស្នាដៃមូលដ្ឋាន :**

- Chomsky Noam, Aspects de la théorie syntaxique, Editions du Seuil, Paris;
- Chomsky Noam, Structures syntaxiques, Editions du Point, Paris;
- Pottier Bernard, Introduction à l'étude des structures grammaticales fondamentales, Publication de la FLSH de Nancy, France;

**ឯកសារសម្រាប់ស្រង់ឧទាហរណ៍ :**

- ពូវ អ៊ុម, វេយ្យាករណ៍ខ្មែរ, បណ្ណាគារ គីម សេង ភ្នំពេញ , ១៩៥៨ ;
- រស្មីកម្ពុជា , សារព័ត៌មានប្រចាំថ្ងៃ ភ្នំពេញ (ខែកក្កដា &ខែសីហា ឆ្នាំ២០០៥)។

**ជាស្នាដៃមូលដ្ឋានផង & ជាឯកសារសម្រាប់ស្រង់ឧទាហរណ៍ផង :**

ពុទ្ធសាសនបណ្ឌិត្យ , វចនានុក្រមខ្មែរ (ក្រោមការទទួលខុសត្រូវរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត) ភ្នំពេញ , ១៩៦៧។

UN APERÇU SUR LE SOY

Jacques RONGIER

Phnom-Penh,Mars 2004

Le **souy** (suoy) est une langue péarique du groupe mon-khmer de la famille austro-asiatique (austro-asiatique > mon-khmer > mon-khmer oriental > péarique > péarique occidental > souy)>). Il est parlé au Cambodge dans l'Oral, province de Kampung Spii, commune de trɔpean Coo, à environ 80 km de la ville de Kampung Spii. Cette commune est sur le point d'être divisée en deux : Trɔpean Coo et C?ɛn . C'est dans la future commune de C?ɛn que vivent les locuteurs souy. Ceux-ci se répartissent dans cinq villages:

Phum Potriə
Phum Kao Dountey
Phum Tanəl
Phum Traan
et Phum cambak .

Les autres langues péariques, toutes parlées au Cambodge, sont :

. lə **s?otch** (sa?och, sauch, saotch) (péarique occidental) parlé près de Prey Nup. En 1981, Wurm et Hattori, évaluaient la population s?otch à 500 individus. Aujourd'hui, le s?otch n'est plus parlé que dans 19 familles et il est en voie d'extinction. Les enfants ne parlent pas.

. le **samre** (péarique occidental), qui était parlé au nord de Siem Reap autour du temple Bantay Samre, est, d'après nos recherches, aujourd'hui éteint. Wurm et Hattori avancaient, en 1981, le chiffre de 200 locuteurs.

. le **somray** (péarique occidental), toujours selon Wurm et Hattori (1981), comptait en tout, environ 2000 locuteurs tout autour de Phum Tasanh et le long de la rivière Tanyong autour de Phum Pra Moi.

. le **chong** (chawng, shong, xong) (péarique occidental) est parlé au Cambodge à la frontière de Thailande au sud-est de Chanteburi dans la province de Pursat. Wurm et Hattori(1981) évaluaient la population chong à environ 5000 personnes au Cambodge et 500 en Thailande. Le chong serait très proche du somray et probablement aussi du souy.




En 1981, Wurm et Hattori faisaient état de 200 locuteurs souy (Ethnologue, 24/01/2000). A la date du 5 octobre 2003, on dénombrait **969 Souy** dont 476 de sexe masculin et 493 de sexe féminin répartis en 214 familles. Les Souy se désignent eux-mêmes par le terme **Sə?uŋ**, à rapprocher probablement de ''chong''. Quant à la langue, on ne lui connaît pas d'autre désignation que [suu?i]. Cette langue est en voie de disparition : les enfants la comprennent mais ne la parlent plus. Tous les Souy sont soit bilingues (souy/khmer), soit monolingues entièrement khmérisés. Il en résulte que les locuteurs actuels utilisent de plus en plus de termes khmers, passent constament d'une langue à l'autre et finissent par mélanger les deux. De plus, il semble qu'il n'y ait pas d'homogénéité au niveau de la prononciation. Les plus jeunes plus en 30 ans réalissent de moins en moins le registre de voix pharyngalisée. Notre première informatrice ne devait pas avoir une conscience très claire du lexique authentiquement souy comparé au lexique khmer. Ses données,

contrôlées par notre informateur de référence, ont dû être dékhmérisées. Par contre le lexique fourni par la plus âgée (la soixantaine) n'a pas été remis en cause.

L'enquête sociolinguistique a été effectuée lors de deux missions de l'Académie Royale du Cambodge, par Prum Moal, Chom Sonnang, By Sokkong et Meakh Bora, et le recueil des données linguistiques par moi-même, le 5 octobre et le 6 décembre 2003, et le 14 février 2004.

Bien que la langue de travail ait été le khmer, les entrées lexicales et les textes ont été pensés à partir du français puis traduits en khmer. Les textes ont été élaborés de façon à tester un certain nombre d'universaux de langage en partant d'intentions de signifier. L'avantage des textes est que les informateurs se fatiguent moins vite que lorsqu'on les assomme de listes de mots ou de phrases "grammaticales" qui n'ont pas de rapport entre elles et risquent de n'avoir ni queue ni tête. De plus les textes apportent un lexique non négligeable. Leurs traductions ont été exhaustivement analysées sur place avant de prendre congé de l'informateur de référence.

Nous allons présenter :

1. un aperçu succinct des réalisations phonétiques
    - 1.1. la syllabe
    - 1.2. les voyelles brèves
    - 1.3. les voyelles longues
    - 1.4. les diphtongues
    - 1.5. les consonnes
    - 1.6. les consonnes finales
    - 1.7. les groupes de consonnes
    - 1.8. les syllabes pharyngalisées
2. le système de transcription adopté.
3. l'ensemble de lexique recueilli, incluant des expressions .
4. les textes phrases par phrases avec mot-à-mot et traduction .
5. Remarques concernant les variantes de traductions

## 1. un aperçu succinct des réalisations phonétiques

### 1.1. la syllabe

V : Voyelle
D : Diphtongue
Vph : Voyelle pharyngalisée
C : Consonne

La syllabe souy est constituée selon les schémas suivants :

| | | |
|---|---|---|
| CVV | [kla:] | *(crier)* |
| CVC | [çʰɑʔ] | *(cracher)* |
| CD | [taɛ] | *(thé)* |
| CDC | [tʰiɜt] | *(se coucher)* |
| CVph | [tʰeˤe] | *(terre)* |
| CVphC | [pʰɔˤɔn] | *(quatre)* |
| CCVV | [pʰli:] | *(fruit)* |
| CCVC | [pruh] | *(blanc)* |
| CCVD | [tᵊŋa:l] | *(front)* |
| CCVph | [tʰmɑˤɑ] | *(pierre)* |
| CCVphC | [ko:ˤɲ] | *(long)* |
| CCD | [ksaɛ] | *(corde)* |
| CCDC | [pruɜh] | *(semer)* |
| CCVVC | [kʰlɑ:ŋ] | *(os)* |

On constate qu'aucune syllabe ne peut commencer par une voyelle. Par ailleurs, le [ᵊ] épenthétique ne doit pas être considéré comme centre de syllabe. [sᵊpiˤi] *(quoi ?)* constitue une seule syllabe. La réalisation [spiˤi] est également courante.

La plupart des mots bisyllabiques semblent formés par adjonction de préfixes ou d'infixes qui ont plus ou moins perdu leur signification d'origine. La première syllabe a alors pour schémas Cə, CVC ou CrV dont la voyelle V est neutralisable et la consonne [r] souvent effacé.

**Schémas «Cə» et «Crə»**

[pəçan] *(lune)*
[kətra:] *(griffe)*

| | |
|---|---|
| [srəma:l] | *(puce)* |
| [krəßat] | *(lancer)* |
| [prəʔap ti:] | *(main)* |
| [trənɜp siiŋ] | *(chaussure)* |

Neutralisation de la voyelle

| | | |
|---|---|---|
| [pɔŋho:jç] | / [pəŋho:jç] | *(tuer)* |
| [runtah] | / [rəntah] | *(tonnerre)* |
| [ɓɑŋßɜl] | / [bəŋßɜl] | *(tourner)* |
| [ɓɑɲrɪɜn] | / [ɓəɲrɪɜn] | *(enseigner)* |
| [kɔnle:ɲ] | / [kənle:ŋ] | *(endroit)* |
| [kɔmlaŋ] | / [kəmlaŋ] | *(fort)* |
| [çumrɪɜp] | / [çəmrɪɜp] | *(informer)* |
| [kɔmplɪɜŋ] | / [kəmplɪɜŋ] | *(joue)* |
| [prɑmaɲ] | / [prəmaɲ] | *(chasser)* |

Effacement de [r]

| | | |
|---|---|---|
| [prəɗap] | / [pəɗap] | *(outil)* |
| [trəçak] | / [təçak] | *(froid, frais)* |
| [prəhɛɛl] | / [pəhɛɛl] | *(peut-être)* |

La consonne finale de l'affixe ne peut être qu'une nasale ([n], [ŋ], [ɲ] ou [m]).

[n] apparaît devant une dentale [d] ou [t] ou la latérale [l] :

| | |
|---|---|
| [kəndɑ:p] | *(gerbe)* |
| [çəntaŋ] | *(petit banc traditionnel)* |
| [kəntu:t] | *(nez)* |
| [kənle:ɲ] | *(endroit)* |

[ɲ] devant la palatale [ç] :

| | |
|---|---|
| [kəɲcak] | *(glace, miroir)* |

[ŋ] devant la vélaire [k], la vibrante [r], la bilabiale fricative [ß] ou une glottale [ʔ] ou [h] :

| | |
|---|---|
| [səŋkra:m] | *(guerre)* |
| [ɓəŋrɪɜn] | *(enseigner)* |

**[ɓəŋßɜl]** *(tourner)*
**[pəŋho:jç]** *(tuer)*
**[çəŋʔiɛt]** *(étroit)*

[m] devant une occlusive bilabiale [p], [pʰ] ou [b], la dentale [n], la latérale [l] ou la vibrante [r] :

**[kɔmplə:ŋ]** *(fusil)*
**[kəmpʰuɜn si:ŋ]** *(mollet)*
**[təmbu:l]** *(toit)*
**[tɔmnɜ:]** *(voyage)*
**[kəmlaŋ]** *(fort)*
**[çəmriɜp]** *(informer)*

D'autres contextes sont probables mais nous nous appuyons uniquement sur les attestations fournies par notre corpus. En tout cas, ces régularités laissent penser que la nasale finale de la première syllabe d'un mot bisyllabique constitue un seul phonème /n/ qui a pour réalisation [n], [ŋ], [ɲ] ou [m] au moins dans les contextes indiqués ci-dessus.

Les mots d'emprunt bisyllabiques tendent à calquer leurs réalisations sur le modèle des bisyllabiques à affixes. Ainsi, [ma:si:n] (machine) tend à se réaliser [məsi:n] ou [məsin].

## 1.2. les voyelles brèves

| | Voyelles antérieures | Voyelles centrales | Voyelles postérieures |
|---|---|---|---|
| fermées | i ?in *(avoir)*<br>sliŋ *(aîné)* | | u pruh *(blanc)* |
| fermées non ATR | ɩ ɩŋ *(moi)*<br>ŋɩç *(verge)*<br>kɩ? *(petit)* | | ʊ jʊɲ *(bois)* |
| semi-fermées | | ə kəp *(corps)*<br>asəm *(homme)* | |
| semi-ouvertes | ɛ kɛh *(pot)* | ɜ kɜl *(s'asseoir)* | ɔ tɔp *(dire)* |
| ouvertes | a sat *(animal)* | | ɑ tɑŋ *(maison)* |

### 1.3. les voyelles longues

| | Voyelles antérieures | Voyelles centrales | Voyelles postérieures |
|---|---|---|---|
| **fermées** | **i:** **si:** *(serpent)* | **ɨ:** **sɨ:t** *(essuyer)*<br>**rəsɨ:** *(tige de bambou)* | **u:** **spu:** *(canne à sucre)* |
| **semi-fermées** | **e:** **re:n** *(parler)*<br>**te:w** *(acheter)*<br>**se:** *(sentir)* | **ə:** **ŋə:p** *(se lever)* | **o:** **po:** *(toi)* |
| **semi-ouvertes** | **ɛ:** **kɛ:** *(aboyer)* | **ɜ:** **hɜ:j** *(déjà)* | **ɔ:** **jɔ:** *(regarder)* |
| **ouvertes** | **a:** **ha:m** *(sang)* | | **ɑ:** **jɑ:** *(balcon avec toit)*<br>**hɑ:p** *(manger)* |

## 1.4. les diphtongues

| à partir de voyelles antérieures | à partir de voyelles centrales | à partir de voyelles postérieures |
|---|---|---|
| iɜ kʰiɜw *(bleu)*<br>iɛ liɛt *(poule)* | iɜ kiɜt *(être malade)*<br>liɜn *(vite)* | uɜ çuɜj *(aider)*<br>kbuɜn *(tuile)* |
| ea pʰlean *(poutre)*<br>eɜ teɜk *(conduire (des animaux))* | əa məat *(oeil)*<br>rəap *(compter)* | oa thoa *(livre)* |
| | aɛ paɛt *(couteau)*<br>aɜ taɜ *(est-ce que...?)*<br>aɔ paɔt *(abattre)*<br>taɔm *(attacher)* | |

| | Bilabiales | Dentales | Palatales | Vélaires | Pharyngale | Glottales |
|---|---|---|---|---|---|---|
| occlusives | p paˤa *(deux)* | t ta:p *(chercher)* | c cɑ:ʔ *(vomir)* | k kah *(mordre)* | | ʔ ʔan *(ceci)* |
| | pʰ pʰa:p *(cassé)* | tʰ tʰuh *(chaud)* | cʰ cʰe:w *(creuser)* | kʰ kʰe:n *(enfant)* | | |
| | ɓ ɓɜŋ *(lac)* | ɗ ɗɔh *(croître)* | | | | |
| fricatives | ß ßa:ʔ *(louche)* | s si: *(serpent)* | j jɔ: *(regarder)* | | ʕ pʰeʕe *(trois)* | h ha:m *(sang)* |
| nasales | m mɔ:t (cadet) | n naʔ (individu) | ɲ ɲə:p *(soulever)* | ŋ ŋiʔ *(vouloir)* | | |
| vibrante | | r rɔ:j *(cent)* | | | | |
| latérale | | l la:ŋ *(laver)* | | | | |

## 1.6 1.6. les consonnes finales

| | | | | |
|---|---|---|---|---|
| **Occlusives** | apico-dentale | t | mɔ:t | *(aîné, plus jeune)* |
| | palatale | ç | ho:jç | *(mourir)* |
| | vélaires | ? | ta? | *(grand)* |
| | | k | tak hɜ:j | *(déjà grand)* |
| | bilabiale | p | t$^{ə}$kɜp | *(sous)* |
| **Nasales** | bilabiale | m | nəm | *(année)* |
| | apico-dentale | n | ?in | *(avoir)* |
| | palatale | ɲ | k$^{h}$u:ɲ | *(père)* |
| | vélaire | ŋ | tɑŋ | *(maison)* |
| **Bilabiale** | semi-voyelle | w | kɛ:w | *(verre)* |
| **Palatale** | semi-voyelle | j | tɑ$^{ʕ}$ɑj | *(avant)* |
| **Fricative** | glottale | h | pruh | *(blanc)* |
| **Latérale** | apico-dentale | l | knu:l | *(sept)* |
| **Vibrante** | apico-dentale | r | ŋɜr | *(rouge)* |

### 1.7. les groupes de consonnes

Les seuls groupes consonantiques pour lesquels nous avons relevé une aspiration de la première consonne sont [p$^{h}$l], [p$^{h}$j], [k$^{h}$l], [k$^{h}$m], [k$^{h}$t] [k$^{h}$ç], [k$^{h}$j], [t$^{h}$n], [t$^{h}$ŋ] et [t$^{h}$m].

| | | | |
|---|---|---|---|
| [p$^{h}$li:] | *(fruit)* | [k$^{h}$mah] | *(fumée)* |
| [p$^{h}$liiɲ] | *(nuage)* | [k$^{h}$ja$^{ʕ}$l] | *(vent)* |
| [p$^{h}$juh] | *(orage)* | [t$^{h}$ŋi:] | *(jour)* |
| [k$^{h}$lɑ:ŋ] | *(os)* | [t$^{h}$nɛ$^{ʕ}$m] | *(plante)* |
| [k$^{h}$la:] | *(route)* | [t$^{h}$ma$^{ʕ}$] | *(pierre)* |
| [k$^{h}$tej] | *(huit)* | | |

Mais cette aspiration n'apparaît pas dans d'autres termes tels que :

| | | |
|---|---|---|
| [ple:w] | *(feu)* | |
| [plam] | *(cinq)* | (qui se dit aussi [pram]) |
| [pla:] | *(nouveau)* | |
| [kɔmplə:ŋ] | *(fusil)* | |

et pour "klaa" (route), nous avons relevé les réalisations [k$^{h}$laa], [klaa] et même [k$^{ə}$laa].

La voyelle épenthétique [ᵊ] est fréquemment introduite entre les deux consonnes des autres groupes.

| | |
|---|---|
| [kᵊna:] | *(ensemble)* |
| [çᵊmɑh] | *(nom)* |
| [çᵊbajç] | *(presser (un citron...))* |
| [tᵊlaʔ] | *(peau)* |
| [tᵊkɜp] | *(en bas)* |

La consonne initiale n'est jamais aspirée dans les groupes [pr], [tr], [cr] et [kr].

| | | |
|---|---|---|
| kr | krən | *(tenir)* |
| çr | çruj | *(remuer)* |
| tr | trɑj | *(boeuf)* |
| pr | pri: | *(forêt)* |

Les tableaux suivants présentent des exemples de chaque groupe de consonnes attestés dans le corpus. La deuxième consonne d'un groupe ne peut être implosive. On a donc [b] et [d] et non [ɓ] et [ɗ]. Les [ᵊ] épenthétiques en variantes libres ne sont pas transcrits et l'aspiration n'est marquée que dans les exemples eux-mêmes et non dans la présentation du groupe. Les cases vides, indiquées par * sont des possibilités qu'on pourrait attendre par comparaison avec le khmer mais pour lesquelles nous n'avons pas d'attestations.

**Première consonne : [p] ou [pʰ]**

| | | |
|---|---|---|
| pʔ | * | |
| pk | pkɔ: | *(tonnerre)* |
| pc | * | |
| pt | * | |
| pd | cap pdɜ:m | *(commencer)* |
| pn | * | |
| pŋ | * | |
| pɲ | * | |
| pj | pʰjuh | *(orage)* |
| pl | pla: | *(nouveau)* |
| pr | pruɜj | *(semer)* |
| ps | psa: | *(marché)* |

**Première consonne : [t] ou [tʰ]**

| | | |
|---|---|---|
| **t?** | ***** | |
| **tk** | **[tka:m]** | *(en bas)* |
| **tp** | ***** | |
| **tb** | ***** | |
| **tn** | **[t$^h$nam]** | *(médicament)* |
| **tŋ** | **[t$^h$ŋɛ:]** | *(écouter)* |
| **tm** | **[t$^h$mɑ$^ʕ$ɑ]** | *(pierre)* |
| **tj** | ***** | |
| **tr** | **[traŋ]** | *(trou)* |
| **tl** | **[tla$^ʕ$j]** | *(large)* |
| **tß** | **[tßar]** | *(porte)* |

**Première consonne : [ç] ou [ç$^h$]**

| | | |
|---|---|---|
| **ç?** | ***** | |
| **çk** | **[çkar]** | *(spatule)* |
| **çd** | ***** | |
| **çp** | **[çpa:?]** | *(hutte)* |
| **çb** | **[çbajç]** | *(presser (un citron))* |
| **çŋ** | **[çŋen]** | *(épouse)* |
| **çn** | ***** | |
| **çm** | **[çmɑh]** | *(nom)* |
| **çl** | **[çlɑŋ]** | *(riz préparé)* |
| **çr** | **[çru:t]** | *(récolter)* |

**Première consonne : [k] ou [k$^h$]**

| | | |
|---|---|---|
| kʔ | * | |
| kc | [$k^h$ce:t] | *(mourir)* |
| kt | [$k^h$tɛj] | *(huit)* |
| kd | [kdɑ:ŋ] | *(six)* |
| kp | * | |
| kb | [kbuɜŋ] | *(tuile)* |
| kn | [knuh] | *(tige de bambou)* |
| kɲ | * | |
| km | [kman] | *(venir)* |
| kj | [$k^h$ja$^ʕ$a] | *(doigt)* |
| kl | [$k^h$laʔ] | *(tomber)* |
| kr | [kra:ɲ] | *(alcool de riz)* |
| ks | [ksaɛ] | *(corde)* |
| kß | * | |

**Première consonne : s**

| | | |
|---|---|---|
| sʔ | sʔa:t | *(joli)* |
| sk | skɑ: | *(sucre)* |
| $sk^h$ | $sk^h$a: | *(savoir)* |
| st | sta:ʔ | *(langue)* |
| sd | sdaɜŋ | *(mince)* |
| sp | spu: | *(canne à sucre)* |
| sb | * | |
| sŋ | sŋal | *(connaître)* |
